# សម្រាកមួយភ្លែត

ឈប់សិន! ឈប់សិន! វិទ្យាសាស្ត្រ
លឿនណាស់ៗ ចក្រអ្នកឯង
ខ្ញុំខំដាយតាមហត់ហួតហែង
សុំឈប់ប្រជែងផ្កាកចលនា។
ខ្ញុំក្រាលស្លឹកឈើក្រោមម្លប់ស្វាយ
ដាក់កាយទម្រេតកើយក្រមា
ខ្យល់បក់ល្វៀកៗល្ហើយកាយា
ចិន្តាហោះហើរហិចទៅឆ្ងាយ។
កាលដើមចង្វាក់នៃជីវិត
ហាក់ឥតរន្ធើនក្តៅក្រហាយ
រង្វើលៗលយអន្លាយ
សប្បាយហូរហែរតាមធម្មតា។



រទេះគោបរស្នូរង៉េតង៉ត
ត្រេតត្រតទ្រយៗកាត់ព្រឹក្សា
ស្នូរស័ព្ទសត្វយំឆ្លងឆ្លើយគ្នា
កំព្រាដួងចិត្តដូចនេនទុំ។
ឯនាយដងទង់ចុងជហ្វា
ដំបូលវិហារកុដមួយដុំ
លេចតាមចន្លោះដើមឈើដុំ
មើលឃើញជម្រំសមជ្រះថ្លា។
ឯនុះដំណែលប្រាង្គប្រាសាទ
ស្អាងស្អាតសុទ្ធសឹងក្បាច់សិលា
មិនដឹងប៉ុន្មានតដូនតា
ឥឡូវព្រឹក្សាដុះព័ទ្ធពើយ។
កាលគ្មានទឹកកកមនុស្សគិតថា
ផឹកទឹកស្រះថ្លាឆ្ងាញ់ណាស់ហើយ
កាលគ្មានឡានលឿនមនុស្សព្រងើយ
ដើរលេងរហើយគ្មានប្រញាប់។
ក្រុងរីកធំឡើងត្រូវទិញខ្យល់
ទិញសព្វគ្មានសល់គ្រប់ប្រដាប់
ទិញណាស់ខ្វះណាស់ខ្វល់ស្ទើរស្លាប់
ស៊ីណាស់រឹតឆាប់ឃ្លានវិញខ្មី។
ចម្រើនសម្រាប់តែចម្រើន
គិតទៅគ្មានកើនលើសជាថ្មី
ខំលូតនាំហត់អត់បានអ្វី
គួរតែលែងខ្វីរត់តាមទៀត៕

**គយ សារុន ឆ្នាំ១៩៦៥**